UNDP Cambodia

# ព្រឹត្តិបត្រព័ត៌មាន

ឆ្នាំទី ០៦ លេខ ២៤
ខែ តុលា - ធ្នូ ឆ្នាំ ២០០៩

ភ្ជាប់ប្រទេសកម្ពុជាទៅនឹងពិភពនៃបទពិសោធន៍លើការអភិវឌ្ឍ

យូអិនឌីភី គឺជាបណ្តាញអភិវឌ្ឍន៍សាកលរបស់អង្គការសហប្រជាជាតិដែលគាំទ្រឱ្យមានការផ្លាស់ប្តូរ និង ភ្ជាប់ប្រទេសនានា ទៅនឹងចំណេះដឹង បទពិសោធន៍ និងធនធានទាំងឡាយដើម្បីជួយប្រជាជនកសាងជីវភាពឱ្យបានប្រសើរឡើង

## ពិពណ៌វិចិត្រសិល្បៈរំលេចអំពីសមិទ្ធផលរបស់កម្ពុជា លើការបោសសំអាតគ្រាប់មីន

ពិពណ៌វិចិត្រសិល្បៈបែបនិម្មិតកម្មមួយ រំលេចអំពីសមិទ្ធផលនៃការបោសសំអាតគ្រាប់មីននៅកម្ពុជា កំពុងតែ ជួយលើកស្ទួយទៅក្នុងឆាកអន្តរជាតិនូវស្នាដៃរបស់វិចិត្រករកម្ពុជាដែលមានទេព្យកោសល្យខ្ពស់មួយចំនួន។ អ៊ីមផាក *(IMPACT): ដែលជាឈ្មោះការតាំងពិពណ៌វិចិត្រសិល្បៈមួយអំពីគ្រាប់មីនបង្កប់ក្នុងដី* គឺជាការរម្លឹកអំពីការរីកចម្រើន យ៉ាងច្រើនរបស់ប្រទេសនេះក្នុងការដោះស្រាយបញ្ហាមីនបង្កប់ក្នុងដី និងសំណល់ជាគ្រាប់ផ្ទុះដែលនៅសេសសល់ពីសម័យសង្គ្រាម។ ពិពណ៌នេះបានប្រារព្ធធ្វើឡើងនៅកម្ពុជាកាលពីខែតុលានេះ ហើយនឹងត្រូវធ្វើដំណើរទៅប្រទេសកូឡុំប៊ីនៅចុងឆ្នាំនេះ ដែលនៅទីនោះវានឹងត្រូវបានគេដាក់តាំងសម្រាប់ជូនតំណាងនានាច្រើនជាង ១០០ ប្រទេសទស្សនា។

លោក តោ វុត្ថា ដែលជាវិចិត្រករម្នាក់ក្នុងចំណោមអ្នកដទៃទៀត ដែលបានចូលរួមនៅក្នុងគម្រោងនេះមានការយល់ដឹងច្រើនពេកណាស់ទៅហើយអំពីគ្រោះថ្នាក់ដែលបង្កដោយគ្រាប់មីន និងគ្រឿងផ្ទុះដែលនៅសេសសល់តាំងពីសម័យសង្គ្រាម។ គាត់កើតនៅឆ្នាំ ១៩៧៥ ក្នុងខេត្តបាត់ដំបង ប៉ុន្តែដោយសារជម្លោះដែលបន្សល់ទុកនៅក្នុងឆ្នាំ ១៩៧៩ គាត់ត្រូវចាកចេញទៅរស់នៅក្នុងជំរុំជនភៀសខ្លួន សាយធូ នៅតាមព្រំដែនកម្ពុជា-ថៃ។

គាត់ពោលរំឭកអំពីអតីតកាលថា "កាលនោះ ខ្ញុំមិនមានវត្ថុសម្រាប់លេងដូចក្មេងនានាក្នុងពេលសព្វថ្ងៃនេះឡើយ។ មិត្តរបស់ខ្ញុំ និងរូបខ្ញុំ លេងតែជាមួយគ្រាប់កាំភ្លើង AK-47 ឬ M16។ នៅពេលខ្ញុំឈ្នះ ខ្ញុំអាចនឹងវាយបំបែកក្បាលគ្រាប់នេះ ដើម្បីយករំសេវដុតលេង ។ វាបន្លឺសម្លេងដូចផាវដូច្នោះដែរ។ ខ្ញុំជាក្មេងមិនដឹងអ្វីទាល់តែសោះ ដោយពុំដឹងអំពីគ្រោះថ្នាក់ពីយុទ្ធភណ្ឌមិនទាន់ផ្ទុះ ឬគ្រាន់មីនបង្កប់ក្នុងដី។ វានៅតែធ្វើឱ្យខ្ញុំខ្លាចនៅពេលដែលខ្ញុំគិតអំពីទង្វើទាំងនេះកាលពីមុន"។

តទៅទំព័រទី២

## មាតិកា

បង្កើនការអត់ឱនខាងនយោបាយនៅកម្ពុជា.............................៣
"អ្នកជើងឯក" ត្រៀមខ្លួនរួចជាស្រេចដើម្បីដឹកនាំការបណ្តុះបណ្តាលអំពីជំនាញតាមដាន និងវាយតម្លៃ..................៤
ដោយសារកិច្ចប្រឹងប្រែងអភិរក្សរបស់អ្នកភូមិត្រីក៏សម្បូរឡើងវិញ.......................................................................៥
អ្នកផលិតប្រហុកបង្កើតជាសមាគមដើម្បីពង្រីកឱកាសខាងទីផ្សារ.......................................................៦

# ឆ្ពោះទៅរកការបង្កើនភាពជាដៃគូក្នុង "បូជនីយកិច្ចលើការប្រែប្រួលអាកាសធាតុ" នៅកម្ពុជា




UNDP PHOTO

*រូបខាងឆ្វេង ឯកឧត្តមទេសរដ្ឋមន្ត្រី បណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរូបខាងស្តាំ លោក ចូ ស្ទ័យើរ នាយកអង្គការ យូអិនឌីភី ប្រចាំកម្ពុជា រួមគ្នាបោះត្រា "Seal the Deal" ដែលជាយុទ្ធនាការសកលអំពាវនាវឱ្យមានការសម្រេចកិច្ចព្រមព្រៀងរួមមួយ នៅក្នុងសន្និសីទលើកទី ១៥ នៃភាគីជាសមាជិកស្តីពីការប្រែប្រួលអាកាសធាតុនៅក្នុងក្រុងកូប៉េនហាក់ ប្រទេសដាណឺម៉ាក នាខែធ្នូនេះ ។*

ការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុកើតមានជាប្រាកដមែន ដែលនឹងបង្កផលប៉ះពាល់ធ្ងន់ធ្ងរមកលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់កម្ពុជា ប្រសិនបើមិនមានកិច្ចប្រឹងប្រែងរួមគ្នាពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗដើម្បីកាត់បន្ថយផលប៉ះពាល់របស់វា មកលើសហគមន៍ដែលងាយរងគ្រោះ និងដាក់ឱ្យអនុវត្តគោលនយោបាយ និងការអនុវត្តមានលក្ខណៈអនុគ្រោះចំពោះបរិស្ថានទេនោះ។

នេះជាសារគន្លឹះមួយចេញពីវេទិកាជាតិកម្ពុជាស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានធ្វើឡើងនៅរាជធានីភ្នំពេញកាលពី ថ្ងៃទី ១៩-២១ ខែតុលា។ វេទិកានេះ ដែលជាលើកដំបូងហើយ មានគោលដៅបង្កើនការយល់ដឹងក្នុងចំណោមស្ថាប័នរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលដើម្បីបង្ហាញថា ការប្រែប្រួលអាកាសធាតុ មិនត្រឹមតែជាបញ្ហាបរិស្ថាននោះឡើយ ក៏ប៉ុន្តែវាក៏ជាបញ្ហាអភិវឌ្ឍន៍ផងដែរ ដោយមានផលវិបាកយ៉ាងច្រើនចំពោះការរីកចម្រើនរបស់ប្រទេសកម្ពុជា ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ នៅក្នុងដំណាក់កាលឈានទៅសន្និសីទលើកទី ១៥ នៃភាគីជាសមាជិកស្តីពីការប្រែប្រួលអាកាសធាតុដែលនឹងធ្វើឡើង នៅក្នុងទីក្រុងកូប៉េនហាក់ នៅក្នុងខែធ្នូ ខាងមុខនេះ វេទិកានេះក៏ផ្តល់នូវឱកាសសម្រាប់កម្ពុជាផងដែរ ដើម្បីធ្វើការពិនិត្យឡើងវិញនូវ ជំហររបស់ខ្លួនសម្រាប់ការពិភាក្សាទាំងនេះ។

ភ្ញៀវចំនួនច្រើនជាង ៧០០ នាក់ ដែលរួមទាំងមន្ត្រីរដ្ឋាភិបាល តំណាងពីបេសកកម្មការទូត និងអង្គការមិនមែនរដ្ឋាភិបាល និស្សិត និងព្រះសង្ឃ បានចូលរួមនៅក្នុងពិធីបើកវេទិកានេះ នៅក្រោមអធិបតីភាពនៃនាយករដ្ឋមន្ត្រី ហ៊ុន សែន។ វត្តមានរបស់ពួកគេបានគូសបញ្ជាក់អំពីកង្វល់ជាមូលដ្ឋាន: ការប្រែប្រួលអាកាសធាតុមានឥទ្ធិពលមកលើមនុស្សគ្រប់រូប - ចាប់តាំងពីអ្នកកសាងគោល នយោបាយ រហូតដល់ប្រជាពលរដ្ឋសាមញ្ញ និងចាប់ពីការអភិវឌ្ឍ រហូតដល់វិស័យឯកជន។

នាយករដ្ឋមន្ត្រីមានប្រសាសន៍ថា វេទិកានេះតំណាងឱ្យ "របត់ថ្មីមួយទៀតនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា" ហើយរដ្ឋាភិបាល និងដៃគូរបស់ខ្លួនត្រូវធ្វើការប្តេជ្ញាដើម្បីឈានទៅអនាគតមួយដែលមាននិរន្តរភាព និងបញ្ចេញកាបូនតិច។

តទៅទំព័រទី២

# ពិពណ៌វិចិត្រសិល្បៈ រំលេចអំពីសមិទ្ធផលរបស់កម្ពុជា.......

*តមកពីទំព័រទី១*

ដោយក្ដីអផ្សុក តោ វុត្ថា បានចាប់ផ្ដើមរៀនសូត្រអំពីរបៀបគូរ និងផាត់ពណ៌ពីអង្គការមួយដែលមាន ឈ្មោះថា Phare និងមានចំណាប់អារម្មណ៍លើវិចិត្រសិល្បៈ។ នៅពេលវិលត្រឡប់មកកម្ពុជាវិញនៅក្នុងឆ្នាំ ១៩៩២ គាត់បានរួមគ្នាបង្កើតសាលា "ពន្លឺសិល្បៈ"។

ក្នុងនាមជាវិចិត្រករដែលបានជ្រើសរើសឱ្យចូលរួមនៅក្នុងពិពណ៌ អ៊ីមផាក *(IMPACT)* ឥឡូវនេះគាត់មានឱកាសដើម្បីប្រើប្រាស់សមត្ថភាពខាងសិល្បៈរបស់ខ្លួនដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីការរីកចម្រើន ដែលបានកើតឡើងនៅក្នុងសកម្មភាពកំចាត់គ្រាប់មីននៅកម្ពុជា។ វិចិត្រករកម្ពុជាចំនួន ១០ រូប បានបង្កើតស្នាដៃសិល្បៈកម្មដែលបង្ហាញពីបញ្ហាទាំងនេះនៅក្រោយបានទៅទស្សនាខេត្តចំនួនពីររបស់កម្ពុជាដែលរងគ្រោះដោយសារគ្រាប់មីន ខ្លាំងជាងគេពោលគឺខេត្តបាត់ដំបង និងបន្ទាយមានជ័យ។ យុវជនចំនួនបួនរូបដែលនៅរួចជីវិតពីគ្រោះថ្នាក់គ្រាប់មីន ក៏បានបង្កើតស្នាដៃសិល្បៈដែលតំណាងឱ្យបទពិសោធន៍ និងមហិច្ឆិតារបស់ពួកគេសម្រាប់អនាគតផងដែរ។

ស្នាដៃសិល្បៈកម្ម រួមមាន បដិមាករ ដែលផលិតចេញពីគ្រាប់មីនដែលគ្មានរំសេវ និងសំណល់គ្រឿងផ្ទុះពីសម័យសង្គ្រាម ផ្ទាំងគំនូរ និងវបបទភណ្ឌ និងមានភ្ជាប់ជាមួយនូវស្នូរសម្លេងដែលបានថតនៅក្នុងអំឡុងពេលធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានជាក់ស្ដែងផងដែរ។

ពិពណ៌នេះបានបើកនៅក្នុងក្រុងភ្នំពេញកាលពីដើមខែតុលា ហើយដោយមានការឧបត្ថម្ភពីរដ្ឋាភិបាល អូស្ត្រាលីនឹងត្រូវធ្វើដំណើរទៅចូលរួមនៅក្នុងសន្និសីទពិនិត្យមើលជាលើកទីពីរនៃសន្ធិសញ្ញាហាមឃាត់គ្រាប់មីន ប្រឆាំងមនុស្សនៅក្នុងខែវិច្ឆិកាឆ្នាំនេះ នាទីក្រុង កាតាហ្សេណាប្រទេសកូឡុំប៊ី។

ឯកអគ្គរដ្ឋទូតនៃប្រទេសអូស្ត្រាលី លោកជំទាវម៉ាហ្គារ៉ែត អាដាំសុន បានពន្យល់ថា "ប្រការសំខាន់គឺប្រជា-ពលរដ្ឋមកពីជុំវិញពិភពលោក ដែលនឹងបានដឹងអំពីការរីកចម្រើន និងការប្រឈមនានាដែលនៅសេសសល់ ទាក់ទងនឹងគ្រាប់មីននៅក្នុងប្រទេសកម្ពុជា"។

រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់សច្ចាប័នលើសន្ធិសញ្ញាហាមឃាត់គ្រាប់មីនប្រឆាំងមនុស្សនៅក្នុងឆ្នាំ ១៩៩៩ ដែលតម្រូវឱ្យបណ្ដារដ្ឋជាភាគី ធ្វើការបោសសំអាតតំបន់ដែលមានបង្កប់គ្រាប់មីនទាំងអស់នៅក្នុងរយៈពេល ១០ ឆ្នាំ។ ដោយសារតែមានបង្កប់គ្រាប់មីនជាច្រើននៅក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលបានលើកស្នើឱ្យមានការបន្ថែមពេល ១០ ឆ្នាំទៀត ដែលនឹងត្រូវពិចារណានៅក្នុងសន្និសីទនេះក្នុងប្រទេសកូឡុំប៊ី។



UNDP PHOTO/JAMES GRANT

*យុវជនបួនរូបនេះ ដែលនៅរួចជីវិតពីគ្រោះថ្នាក់គ្រាប់មីន បានបង្កើតស្នាដៃក្នុងការតាំង ពិពណ៌វិចិត្រសិល្បៈបែបនិម្មិតកម្មមួយ រំលេចអំពីសមិទ្ធផលនៃការបោសសំអាតគ្រាប់មីននៅកម្ពុជា កាលពីខែតុលាកន្លងទៅនេះ។ ពិពណ៌នេះ នឹងត្រូវធ្វើដំណើរទៅ ប្រទេស កូឡុំប៊ី នៅចុងឆ្នាំនេះ ដែលនៅទីនោះវានឹងត្រូវបានគេដាក់តាំងសម្រាប់ជូនតំណាងនានាច្រើនជាង ១០០ ប្រទេស ទស្សនា។*

លោក តោ វុត្ថា បានពោលថា "ឥឡូវនេះ ខ្ញុំយល់យ៉ាងច្រើនអំពីបញ្ហានានានៅជុំវិញសកម្មភាពកំចាត់គ្រាប់មីន ហើយខ្ញុំរីករាយណាស់ ដែលមានឱកាសដើម្បីបង្ហាញផ្ទាំងគំនូររបស់ខ្ញុំនៅក្នុងពិពណ៌វិចិត្រសិល្បៈនេះ"។

# ឆ្ពោះទៅរកការបង្កើនភាពជា...

*តមកពីទំព័រទី១*

បើទោះជាកម្ពុជាមានចំណែកតិចតួចបំផុតនៅក្នុងបរិមាណសរុបនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងពិភពលោកក៏ដោយ ឯកឧត្ដមទេសរដ្ឋមន្ត្រី បណ្ឌិត ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថានមានប្រសាសន៍ថា រដ្ឋាភិបាលមានការប្ដេជ្ញាដើម្បីធ្វើការជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅ "ក្នុងបូជនីយកិច្ចលើការប្រែប្រួលអាកាសធាតុ"។

ឯកឧត្ដម មានប្រសាសន៍នៅក្នុងវេទិកានេះ ដែលបានរៀបចំឡើងដោយក្រសួងបរិស្ថាន និងក្រោមការគាំទ្រពីដានីដា ស៊ីដា អុកស្វាម និងយូអិនឌីភី ថា "យើងចង់ក្លាយខ្លួនជាផ្នែកមួយនៃដំណោះស្រាយបញ្ហាពិភពលោកនេះ ដោយសារឆន្ទៈនយោបាយ និងការទទួលខុសត្រូវខាងសីលធម៌របស់យើង។ ប្រការសំខាន់ជាងនេះទៀតដោយសារដំណោះស្រាយចំពោះការប្រែប្រួលអាកាសធាតុពិតជាមានប្រយោជន៍ខាងនយោបាយ សេដ្ឋកិច្ច បរិស្ថាន និងបច្ចេកវិទ្យា"។

នៅក្នុងរបៀបវារៈនៃវេទិកានេះ មានបញ្ហាគន្លឹះនានាដែលទាក់ទងជាមួយការប្រែប្រួលអាកាសធាតុ ដូចជាការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ អ្នកចូលរួមបានពិនិត្យមើលទម្លាប់អនុវត្តល្អៗនៅក្នុងប្រទេសដទៃទៀត និងបានពិចារណាអំពីវិធីល្អៗដើម្បីបញ្ជ្រាបចំណាត់ការប្រហាក់ប្រហែលគ្នានេះ ទៅក្នុងវិស័យនានានៃការអភិ-វឌ្ឍនៅកម្ពុជា។

ភាពងាយរងគ្រោះរបស់កម្ពុជាចំពោះមុខការប្រែប្រួលអាកាសធាតុមានកម្រិតខ្ពស់ណាស់ ដោយសារសមត្ថភាពខាងហិរញ្ញវត្ថុ បច្ចេកវិទ្យា និងស្ថាប័ន ដែលមានក្នុងកម្រិតកំណត់សម្រាប់បន្សាំទៅនឹងការប្រែប្រួល និងឆ្លើយតបទៅនឹងឥទ្ធិពលនានា។ ជាប្រទេសមួយដែលប្រជាពលរដ្ឋប្រមាណ ៨0% នៃប្រជាពលរដ្ឋសរុប ១៣.៤ លាននាក់ រស់នៅតាមជនបទនិងពឹងផ្អែកជាសំខាន់លើកសិកម្មសម្រាប់ការរស់នៅ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នឹងមានឥទ្ធិពលយ៉ាងខ្លាំងផងដែរមកលើសន្តិសុខស្បៀងនៅក្នុងប្រទេសកម្ពុជា។ ព្យុះត្រូពិក ឈ្មោះកេតសាណា នាពេលថ្មីៗនេះដែលបានបក់បោកមកលើភូមិភាគកណ្ដាលនៃប្រទេសនេះនៅក្នុងខែកញ្ញា ដែលបានបង្កឱ្យមានទឹកជំនន់ ការខូចខាតផ្ទះសំបែងជាច្រើនរយខ្នង និងការបាត់បង់ជីវិត បានបង្ហាញថាប្រទេសនេះពុំមានសមត្ថភាពដើម្បីតស៊ូនឹងគ្រោះមហន្តរាយធម្មជាតិបែបនេះឡើយ។

ប៉ុន្តែ ក្នុងចំណោមការប្រឈមនានា ក៏មានឱកាសជាច្រើនផងដែរ។

អ្នកសម្របសម្រួល អ.ស.ប ប្រចាំនៅកម្ពុជា និងជាតំណាងអង្គការយូអិនឌីភីនៅកម្ពុជា លោក ឌូក្លាស់ ប្រូឌើរិក មានប្រសាសន៍ថា ការប្រែប្រួលអាកាសធាតុ គឺជាអាទិភាពមួយនៅក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់ អ.ស.ប សម្រាប់កម្ពុជាសម្រាប់ឆ្នាំ ២០១១-២០១៥។ ការអភិវឌ្ឍសមត្ថភាពរបស់អាជ្ញាធរជាតិ និងក្នុងមូលដ្ឋានសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីលើកកំពស់ការបន្សាំ ចំពោះការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនឹងក្លាយជាផ្នែកសំខាន់មួយនៃក្របខ័ណ្ឌជំនួយនេះ។

កម្ពុជាគឺជាប្រទេសតែមួយគត់ដែលត្រូវបានជ្រើសរើសសម្រាប់ការអនុវត្តសាកល្បងនូវកិច្ចផ្ដួចផ្ដើមហិរញ្ញប្បទានពិភពលោកចំនួនពីរសម្រាប់ការបន្សាំ ពោលគឺកម្មវិធីសាកល្បងដែលចាត់ចែងដោយធនាគារពិភពលោកសម្រាប់ភាពធន់នឹងអាកាសធាតុ និងសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុពិភពលោករបស់គណៈកម្មការសហគមន៍អឺរ៉ុប។

នាយកធនាគារពិភពលោកប្រចាំនៅកម្ពុជា លោក គីម៉ាវ ហ្វាន មានប្រសាសន៍ថា កម្មវិធីសាកល្បងនេះនឹងផ្ដល់ទឹកប្រាក់ពី ៣០ ទៅ ៦០ លានដុល្លារអាមេរិក សម្រាប់សកម្មភាពនានា ដើម្បីពង្រឹងអាទិភាពអភិវឌ្ឍន៍ជាតិរបស់កម្ពុជា និងធ្វើឱ្យអាទិភាពទាំងនោះកាន់តែធន់នឹងការប្រែប្រួលអាកាសធាតុ។

សព្វថ្ងៃនេះ អង្គការយូអិនឌីភីនៅកម្ពុជា កំពុងជួយសម្របសម្រួលក្នុងការតាក់តែងតំណាក់កាលទីមួយនៃកម្មវិធីសាកល្បងនេះ។ ជាមួយគ្នានេះដែរ អង្គការនេះក៏ត្រូវបានគេស្នើឱ្យធ្វើជាអ្នកគ្រប់គ្រងមូលនិធិត្រាស់នៃសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុពិភពលោករបស់គណៈកម្មការសហគមន៍អឺរ៉ុបផងដែរ។

យូអិនឌីភី បានជួយរដ្ឋាភិបាលកម្ពុជានៅក្នុងការអភិវឌ្ឍសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងនៅក្នុងការរៀបចំរបាយការណ៍ជាតិលើកទីមួយ ដែលជាមូលដ្ឋានសម្រាប់ការបង្កើតកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ(NAPA)។ បច្ចុប្បន្ន យូអិនឌីភី កំពុងបន្តការគាំទ្ររបស់ខ្លួនដល់រដ្ឋាភិបាលក្នុងការរៀបចំរបាយការណ៍ជាតិលើកទីពីរ ដែលជាយថាហេតុនឹងនាំទៅដល់ការបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ។

នាយកអង្គការយូអិនឌីភី លោក ចូ ស្ក័យើរ បានពោលនៅក្នុងវេទិកានេះថា នៅក្នុងការកសាងជំហានទាំងនេះកម្ពុជាអាចនាំមុខនៅក្នុងការកសាងសេដ្ឋកិច្ចបៃតងដែលបញ្ចេញកាបូនតិច។ លោកបានបន្ថែមថា ក្នុងពេលដែលការប្ដេជ្ញា និងការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍មានសារៈសំខាន់ជាស្នូល ការសម្របសម្រួលបានល្អក្នុងចំណោមពួកគេ ក៏មានសារៈសំខាន់ដូចគ្នាផងដែរ។

លោកបានពោលថា "ធនធានបន្ថែមទៀតជាច្រើននឹងអាចផ្ដល់មកឱ្យកម្ពុជាដើម្បីដោះស្រាយការបន្សាំ និងការកាត់បន្ថយ ការប្រែប្រួលអាកាសធាតុ។ អាស្រ័យហេតុនេះ ប្រការសំខាន់គឺ យន្តការសម្របសម្រួល និងការចែករំលែកព័ត៌មានត្រូវតែរឹងមាំ គ្រប់គ្រាន់ ដើម្បីធានាឱ្យការឆ្លើយតបរបស់ជាតិមានប្រសិទ្ធភាព និងផ្ដល់ផល"។

បន្ទាប់ពីវេទិកានេះ និងដើម្បីបន្តការប្ដេជ្ញាក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ កម្ពុជានឹងបញ្ជូនមន្ត្រីរដ្ឋាភិបាល ប្រមាណ ២០ រូបពីក្រសួងពាក់ព័ន្ធនានាទៅចូលរួមប្រជុំនៅក្នុងសន្និសីទលើកទី ១៥ នៃភាគីជាសមាជិកស្ដីពីការប្រែប្រួលអាកាសធាតុ នៅក្នុងក្រុងកូប៉ែនហាក់ នាខែធ្នូខាងមុខនេះ។ អង្គការយូអិនឌីភីនៅកម្ពុជា ក៏នឹងចូលរួមនៅក្នុងសន្និសីទនេះផងដែរដែលផ្ដល់ជាការគាំទ្រខាងបច្ចេកទេសនឹងយោបល់ដល់មន្ត្រីកម្ពុជា ដើម្បីចូលរួមយ៉ាងសកម្ម និងដែលមានប្រយោជន៍នៅក្នុងការចរចានានា។

# បង្កើនការអត់ឱនខាងនយោបាយនៅកម្ពុជា

ស្ថានភាពប្រជាធិបតេយ្យនៅកម្ពុជាត្រូវបានលើកឡើងនៅលើឆាកនៅពេលដែលអ្នកតាក់តែងច្បាប់មកពីគណបក្សនយោបាយខុសៗគ្នា បានអង្គុយជាមួយគ្នា នៅក្នុងសិក្ខាសាលាមួយ ដើម្បីប្រារព្ធទិវាអន្តរជាតិនៃប្រជាធិបតេយ្យ នៅថ្ងៃទី ១៥ ខែ កញ្ញា។ នៅក្រោមប្រធានបទ **"ប្រជាធិបតេយ្យ និងការអត់ឱនខាងនយោបាយ"** ព្រឹត្តិការណ៍នេះបង្ហាញពីការជជែកវែកញែករស់រវើក ជាពិសេសរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងលើការរីកចម្រើន និងទិសដៅនៃការ អនុវត្តប្រជាធិបតេយ្យនៅក្នុងប្រទេសនេះ។

លោកស្រី ស៊ូសាន ខោលី ទីប្រឹក្សាជាន់ខ្ពស់របស់យូអិនឌីភី មានប្រសាសន៍ថា បើទោះជាមានការសំដែងទស្សនៈខុសគ្នាក៏ដោយនេះគឺជាផ្នែកសំខាន់មួយដើម្បីពង្រឹងប្រជាធិបតេយ្យ។ លោកស្រីបានពោលថា "ព្រឹត្តិការណ៍នេះមានគោលបំណងជួយ សភាក្នុងការផ្តល់ចន្លោះឱកាសខាងនយោបាយដើម្បីធ្វើការជជែកវែកញែកអំពីស្ថានភាពប្រជាធិបតេយ្យនៅកម្ពុជា ដែលចន្លោះឱកាសបែបនេះវាមិនមាននាបច្ចុប្បន្នបើគ្មានវេទិកាបែបនេះ"។

លោកស្រីបានបន្ថែមថា "ព្រឹត្តិការណ៍នេះបង្ហាញថាអ្នកពាក់ព័ន្ធទាំងអស់នៅកម្ពុជា អាចចូលមកជួបគ្នាតាមវិធីដែលមានការគិតគូររួម និងប្រកបដោយការស្តាបនា និងពិភាក្សាអំពីបញ្ហាដែលមានសារៈសំខាន់ជាមូលដ្ឋានគ្រឹះដូចជាប្រជាធិបតេយ្យ។ មូលដ្ឋានគ្រឹះនៃប្រជាធិបតេយ្យគឺការចូលរួម និងការផ្លាស់ប្តូរទស្សនៈផ្ទុយគ្នា"។

រដ្ឋសភាជាតិកម្ពុជាបានចាត់ចែងឱ្យមានព្រឹត្តិការណ៍នេះឡើងក្រោមការគាំទ្រពីអង្គការ ខុនរ៉ាត់ អាដេណូអ័រ ស្ទីហ្វទុង សហភាពអន្តរសភា និងយូអិនឌីភី។ នេះជាលើកដំបូងនៅក្នុងសកម្មភាពរបស់សភា ដែលក្រុមពហុភាគីមួយត្រូវបានបង្កើតឡើង ដើម្បីធ្វើការឆ្លើយតប និងរួមវិភាគទានទៅក្នុងតួនាទីរបស់គណបក្សនយោបាយ ដើម្បីពង្រឹងប្រជាធិបតេយ្យនៅកម្ពុជា។

ប៉ុន្តែ ព្រឹត្តិការណ៍នេះមិនត្រឹមតែមានការចូលរួមពីគណបក្សនយោបាយប៉ុណ្ណោះទេ។ មានអ្នកចូលរួមច្រើនជាង ២00 នាក់ ដែលរួមទាំងតំណាងនានាមកពីស្ថានទូតបរទេស សង្គមស៊ីវិល ក្រុមជនភាគតិច និងប្រព័ន្ធផ្សព្វផ្សាយដែលបានចូលរួមនៅក្នុងការពិភាក្សានានា អំពីស្ថានភាពប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ អភិបាលកិច្ចល្អ សេរីភាពក្នុងការសំដែងមតិ និងចំណងទាក់ទងរបស់ពួកគេទៅនឹងការកាត់បន្ថយភាពក្រីក្រ។

ភាពមិនលំអៀងនៃការជជែកវែកញែកនេះ ត្រូវបានធានាតាមរយៈអ្នកសម្របសម្រួលវគ្គនានា ដែលធ្វើឡើងដោយឯកអគ្គរដ្ឋទូតមកពីចក្រភពអង់គ្លេស អាល្លឺម៉ង់ សហរដ្ឋអាមេរិក និងអូស្ត្រាលី។ សមាជិកព្រឹទ្ធសភាមួយរូបមកពីហ្វីលីពីន និងសមាជិកសភាមួយរូបមកពីប្រទេសម៉ាឡេស៊ី ក៏បានចូលរួមចែករំលែកបទពិសោធន៍របស់ខ្លួនអំពីការអភិវឌ្ឍប្រជាធិបតេយ្យ នៅក្នុងប្រទេសរបស់ខ្លួនផងដែរ។

ថ្លែងក្នុងនាមជាក្រុមអ្នកជំនាញ សមាជិកព្រឹទ្ធសភាមកពីប្រទេសហ្វីលីពីន អាគីលីណូ ពីម៉ិនតែល បានបកស្រាយអំពីរបៀបដែលក្រុមជំទាស់នៅក្នុងប្រទេសរបស់ខ្លួនធ្លាប់ត្រូវគេឱ្យឈ្មោះថា "សត្រូវ" នៅក្នុងការសំដែងទស្សនៈខុសពីក្រុមដែលកាន់ កាប់អំណាចនៅក្នុងរដ្ឋាភិបាល។ តាមទស្សនៈរបស់គាត់ គណបក្សប្រឆាំងមានតួនាទីសំខាន់មួយនៅក្នុងដំណើរការយោបាយ ប្រសិនបើចង់ឱ្យប្រជាធិបតេយ្យដំណើរការបានរីកចម្រើន។ តាមរយៈការសង្កេតអំពីភាពតានតឹងនៅក្នុងការពិភាក្សារវាងអ្នកនយោបាយកម្ពុជានៅក្នុងសិក្ខាសាលានោះ លោកបានពោលថា "ខ្ញុំមើលឃើញថា ប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា នៅមានជីវិតនៅឡើយ"។

លោក សម រង្ស៊ី ដែលជាប្រធានគណបក្សប្រឆាំងសមរង្ស៊ី បានអំពាវនាវឱ្យមានការរួមបញ្ចូលគណបក្សនយោបាយទាំងអស់នៅក្នុងការធ្វើសេចក្តីសម្រេច។ គណបក្សរបស់លោក ស្ថិតក្នុងចំណោមគណបក្សចំនួនប្រាំដែលមានអាសនៈនៅក្នុងចំណោម អាសនៈសរុបចំនួន ១២៣ នៅក្នុងរដ្ឋសភាជាតិ។

លោកបានពោលថា "ដំណើរការធ្វើសេចក្តីសម្រេចគួរតែផ្អែកលើការចូលរួមពីគណបក្សនយោបាយដទៃ និងប្រជាពលរដ្ឋ"។

លោក សម រង្ស៊ី ក៏បានសំដែងការព្រួយបារម្ភផងដែរថាកម្ពុជានៅត្រូវធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយមុននឹងក្លាយជាប្រទេសមួយដែលមានប្រជាធិបតេយ្យពិតប្រាកដ។ ទោះជាយ៉ាងណាក៏ដោយ វាគ្មិនមកពីគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាច មិនឯកភាពចំពោះមតិនេះឡើយ។

លោក ស៊ីន ប៊ុនហុក ដែលជាអ្នកតាក់តែងច្បាប់មកពីគណបក្សកាន់អំណាចបានពោលថា "ប្រជាធិបតេយ្យនៅកម្ពុជាកំពុងរីកចម្រើន ប៉ុន្តែយើងមិនអាចប្រៀបធៀបនឹងប្រជាធិបតេយ្យនៅក្នុងប្រទេសផ្សេងបានឡើយ"។

កម្ពុជាបានចាប់ផ្តើមគូសវាសលំនាំនៃប្រជាធិបតេយ្យរបស់ខ្លួននៅក្នុងឆ្នាំ ១៩៩៣ នៅពេលដែលការបោះឆ្នោតតាមបែបប្រជាធិបតេយ្យជាលើកដំបូង បានធ្វើឡើងក្រោមការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ។ បន្ទាប់ពីមានអំពីហឹង្សាជាច្រើនទស្សវត្សរ៍កន្លងមក ប្រទេសនេះបានជួបនឹងការប្រឈមជាច្រើន ក្នុងការព្យាយាមអភិវឌ្ឍន៍ស្ថាប័នប្រជាធិបតេយ្យ និងកែលម្អស្តង់ដារនៃការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។

ក្នុងនាមជាសាក្សីនៅក្នុងការជជែកវែកញែកនេះ តំណាងមួយរូបមកពីអង្គការជនពិការកម្ពុជាមានអារម្មណ៍ថាការយកចិត្តទុកដាក់ជាច្រើនបានផ្តោតតែលើទិដ្ឋភាពនយោបាយនៃសេរីភាពខាងប្រជាធិបតេយ្យ ប៉ុន្តែមិនបានផ្តោតគ្រប់គ្រាន់លើតម្រូវការចាំបាច់ដើម្បីបង្កើនការចូលរួមរបស់ជនពិការនៅក្នុងដំណើរការអភិវឌ្ឍន៍ឡើយ។

លោក អ៊ាង ចាន់ដារ៉ា មន្ត្រីជាន់ខ្ពស់នៃកម្មវិធីរបស់អង្គការជនពិការកម្ពុជា ដែលខ្លួនឯងផ្ទាល់ក៏ជាជនពិការម្នាក់ផងដែរនោះ បាននិយាយថា "ជនពិការ គឺជាផ្នែកមួយនៃសង្គម។ ពួកគេងាយរងគ្រោះបំផុត និងក្រីក្របំផុតនៅក្នុងប្រទេសកម្ពុជា។ ពួកគេចង់ចូលរួមដោយសេរីនៅក្នុងសង្គមដើម្បីកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ខ្លួន។ គ្មាននរណាម្នាក់ដឹងអំពីការលំបាករបស់ជនពិការ ជាងជនពិការខ្លួនឯងឡើយ ដូច្នេះការចូលរួមរបស់យើងនៅក្នុងសកម្មភាពសង្គមមានសារៈសំខាន់ណាស់សម្រាប់ដោះស្រាយបញ្ហារបស់យើង"។

លោកស្រី ស៊ូសាន ខោលី មកពីអង្គការ យូអិនឌីភី បានពោលថា គាត់បានសង្ឃឹមថា សិក្ខាសាលានេះបង្កើតជាមូលដ្ឋានសម្រាប់ផ្តល់ឱកាសជាច្រើនដល់ការពិភាក្សានានាទៅអនាគត អំពីការពង្រឹងប្រជាធិបតេយ្យនៅកម្ពុជា"។



UNDP PHOTO

*លោក អ៊ាង ចាន់ដារ៉ា មន្ត្រីកម្មវិធីជាន់ខ្ពស់នៃអង្គការជនពិការកម្ពុជា ចូលរួមពិភាក្សានៅក្នុងសិក្ខាសាលាមួយ ដើម្បីប្រារព្ធ ទិវាអន្តរជាតិនៃប្រជាធិបតេយ្យ នៅថ្ងៃទី ១៥ ខែ កញ្ញា កន្លងទៅនេះ។ នៅក្រោមប្រធានបទ "ប្រជាធិបតេយ្យ និងការអត់ឱនខាងនយោបាយ" ព្រឹត្តិការណ៍នេះបង្ហាញពីការជជែកវែកញែករស់រវើកជាពិសេសរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងលើការរីកចម្រើន និងទិសដៅនៃការអនុវត្តប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។*

# “អ្នកដើងឯក” ត្រៀមខ្លួនរួចជាស្រេចដើម្បីដឹកនាំការបណ្តុះបណ្តាល អំពីជំនាញតាមដាន និងវាយតម្លៃ

ជាសមាជិកមួយរូបនៅក្នុងមន្ទីរកិច្ចការនារីខេត្តប៉ៃលិន នាង ជួប ខេមនិក ធ្លាប់តែរង់ចាំទទួលការណែនាំពីប្រធានរបស់គាត់ មុននឹងធ្វើសកម្មភាពតាមដាន និងវាយតម្លៃ ដែលអនុវត្តដោយមន្ទីររបស់គាត់។ បច្ចុប្បន្ន គាត់បង្រៀនអ្នកដទៃទៀត អំពីរបៀបអនុវត្តការងារទាំងនេះ។

គាត់ជាស្ត្រីម្នាក់ ក្នុងចំណោមមន្ត្រីទាំង ៤៨ នាក់ នៅក្នុងមន្ទីរកិច្ចការនារីខេត្ត-ក្រុងនៅទូទាំងប្រទេស ដែលត្រូវបានគេ ស្គាល់ផងដែរថាជាជើងឯក។ ពួកគាត់បានទទួលងារ ដែលមិនទាក់ទងជាមួយការប្រកួតប្រជែងក្នុងកីឡាឡើយ ក្រោយពីបានបញ្ចប់ការបណ្តុះបណ្តាលជាបន្តបន្ទាប់ ដែលអនុញ្ញាតឱ្យពួកគាត់ក្លាយជាគ្រូបង្ហាត់លើការងារតាមដាន និងវាយតម្លៃក្នុងចំណោមក្រុមអ្នកធ្វើការដូចគ្នា។

នាង ជួប ខេមនិក បានពោលថា "ខ្ញុំបានទទួលចំណេះដឹង និងរៀនសូត្រអំពីជំនាញថ្មីៗ ដែលខ្ញុំអាចយកទៅអនុវត្តនៅក្នុងការងារប្រចាំថ្ងៃរបស់ខ្ញុំ និងចែករំលែកចំណេះដឹងនេះជាមួយជន បង្គោលទទួលខុសត្រូវលើការតាមដាន និងវាយតម្លៃ"។

គាត់ ជាមនុស្សម្នាក់ក្នុងចំណោមជើងឯកពីររូបមកពីខេត្តប៉ៃលិន ដែលជាតំបន់ស្ថិតក្រោមការគ្រប់គ្រងចុងក្រោយនៃពួកឧទ្ទាមខ្មែរក្រហម រហូតដល់ឆ្នាំ ១៩៩៦។ តំបន់នេះបានធ្វើសមាហរណកម្មទៅក្នុងរដ្ឋាភិបាលកាលពី ១៣ ឆ្នាំមុន ហើយសព្វថ្ងៃនេះ គឺជាខេត្តនាំមុខមួយក្នុងចំណោមខេត្តនានានៅក្រោមកំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន ដែលការទទួលខុសត្រូវនានាកំពុងត្រូវបានផ្ទេរពីអាជ្ញាធរថ្នាក់ជាតិទៅថ្នាក់មូលដ្ឋាន ដើម្បីផ្តល់សេវាកម្មជាច្រើនដល់ប្រជាពលរដ្ឋ។

រដ្ឋាភិបាលកម្ពុជាបានសម្រេចថា កំណែលម្អអភិបាលកិច្ច ឬ វិមជ្ឈការ និងវិសហមជ្ឈការ គឺជាលក្ខខណ្ឌចាំបាច់សម្រាប់លើកកំពស់អភិបាលកិច្ចល្អ និងកាត់បន្ថយភាពក្រីក្រ។ ការអភិវឌ្ឍចំណេះដឹង និងកែលម្អជំនាញបច្ចេក-ទេសរបស់មន្ត្រីនានានៅថ្នាក់ក្រោមជាតិ ត្រូវបានចាត់ទុកថាជាប្រការសំខាន់បំផុតមួយនៃការសម្រេចគោលដៅនេះ។

ជើងឯកទាំងនេះ មកពីគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តនានា ដែលមាននាទីជាយន្តការសំខាន់មួយសម្រាប់សម្របសម្រួលការកសាងផែនការ និងការអនុវត្តគម្រោងអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន និងមកពីមន្ទីរពាក់ព័ន្ធនានា។ ពួកគេបានពាក់ព័ន្ធនៅក្នុងការតាមដាន និងវាយតម្លៃលើការវិនិយោគ និងសេវាកម្មនានាដែលជម្រុញឱ្យមានអភិបាលកិច្ចល្អ និងកាត់បន្ថយភាពក្រីក្រ។ ពួកគេត្រូវបានជ្រើសរើស ដោយសារតែមានទឹកចិត្តមោះមុតនៅក្នុងការជម្រុញការងារតាមដាន និងវាយតម្លៃ។

នៅរវាងខែឧសភា និងសីហា ឆ្នាំនេះ ពួកគេបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលចំនួនបួន។ មេរៀននៅក្នុងវគ្គទាំងនោះ រួមមានវិធីតាក់តែងមេរៀន ចាត់ចែងនឹងផ្តល់ការបណ្តុះបណ្តាល និងនៅទីបំផុតធ្វើការវាយតម្លៃអំពីឥទ្ធិពលនៃការបណ្តុះបណ្តាលនោះ។ ឧបករណ៍សោតទស្សន៍ ល្បែង និងលំហាត់នានា ត្រូវបានដាក់ឱ្យប្រើប្រាស់ជាឧទាហរណ៍ដើម្បីបង្កើតបរិយាកាសមួយសម្រាប់ឱ្យសិក្ខាកាមទាំងអស់បានចូលរួមយ៉ាងសកម្ម។

ជើងឯកនានាដែលរួមមាន ស្ត្រីចំនួន ១២ រូបផងដែរនោះត្រូវបានគេរំពឹងថា នឹងអាចចាត់ចែងឱ្យមានវគ្គបណ្តុះបណ្តាលទៅអនាគត ដែលនឹងឆ្លើយតបទៅតាមតម្រូវការចាំបាច់ និងបញ្ហាជាក់លាក់សម្រាប់សហគមន៍នីមួយៗ។

សកម្មភាពទាំងនេះ គឺជាផ្នែកមួយនៃគម្រោងសាកល្បងដែលគាំទ្រដោយ យូអិនឌីភី ដើម្បីកែលម្អចំណេះដឹងនិងជំនាញរបស់មន្ត្រីខេត្ត និងជនបង្គោលនានាលើការតាមដាននិងវាយតម្លៃ។ គម្រោងនេះគឺជាផ្នែកមួយនៃក្របខ័ណ្ឌការងាររបស់ យូអិនឌីភី ដើម្បីពង្រឹងប្រព័ន្ធនិងរចនាសម្ព័ន្ធរដ្ឋបាលនៅមូលដ្ឋាន និងផ្តល់ឱ្យពួកគេនូវអំណាចធ្វើសេចក្តីសម្រេចកាន់តែច្រើនជាងមុន ដើម្បីអាចឱ្យពួកគេផ្តល់សេវាកម្មបានឆាប់រហ័សជាងមុនទៅដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

នៅក្នុងតួនាទី និងការងាររបស់ខ្លួនជាជើងឯកនៅក្នុងខេត្តប៉ៃលិន នាង ជួប ខេមនិក អាចធ្វើការជាមួយគ្រូបង្ហាត់ ជាមួយជើងឯកដទៃទៀតនៅក្នុងខេត្តនេះ និងបានទទួលការគាំទ្រ ការបង្ហាត់បង្រៀន និងការណែនាំបច្ចេកទេសបន្ថែមពីគ្រូបង្ហាត់ច្បងផងដែរ។

គាត់ពោលថា "បើគ្មានជំនាញ និងចំណេះដឹងទេនោះ បុគ្គលិករបស់យើងនៅថ្នាក់ខេត្តមិនអាចផ្តល់សេវាកម្មនានាទៅដល់ប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយប្រសិទ្ធិភាពដូចដែលយើងចង់ឃើញនោះឡើយ"។

លោក តេក គីមសុង ជើងឯកមួយរូបទៀតមកពីមន្ទីរកសិកម្ម នៅក្នុងខេត្តស្ទឹងត្រែងបានឯកភាពចំពោះយោបល់នេះ។

លោកបានពោលថា មុនបានឆ្លងកាត់វគ្គបណ្តុះបណ្តាលនេះ គាត់មិនបានដឹងថាការយល់ដឹងបានពេញលេញអំពីដំណើរការ និងនីតិវិធីតាមដាន និងវាយតម្លៃមានសារៈសំខាន់បែបនេះឡើយ។ ចាប់តាំងពីនោះមកការបណ្តុះបណ្តាលបានធ្វើឱ្យគាត់ ផ្លាស់ប្តូរទស្សនៈវិស័យរបស់ខ្លួន។

គាត់បានពោលថា "វាជារឿងថ្មីបំផុតសម្រាប់ខ្ញុំ។ កាលពីដំបូងខ្ញុំមិនទាន់ដឹងច្បាស់ទេថា ខ្ញុំនឹងអាចរៀនបានគ្រប់ប្រធានបទនៅក្នុងវគ្គបណ្តុះបណ្តាលនេះឡើយ។ វាជាការគួរឱ្យខ្លាចផងដែរ។ ប៉ុន្តែឥឡូវនេះខ្ញុំទទួលបានចំណេះដឹង និងជំនាញថ្មីដែលមានសារៈសំខាន់ជាទីបំផុតសម្រាប់រូបខ្ញុំ នៅពេលដែលខ្ញុំសម្របសម្រួលការបណ្តុះបណ្តាលប្រហាក់ប្រហែលគ្នានេះសម្រាប់អ្នកដទៃនៅពេលអនាគត"។

គាត់បានបន្ថែមថា នៅក្នុងបរិបទនៃកំណែទម្រង់សព្វថ្ងៃនេះ ការអនុវត្តគម្រោងណាមួយនឹងមិនមានប្រយោជន៍ឡើយ ប្រសិនបើយើងមិនដឹងអំពីរបៀបធ្វើការតាមដាន និងវាយតម្លៃទេនោះ"។




UNDP PHOTO

*រូបភាពនេះតំណាងឱ្យវគ្គបណ្តុះបណ្តាលគ្រូបង្គោល អំពីជំនាញតាមដាន និងវាយតម្លៃ។ វគ្គបណ្តុះបណ្តាលនេះ គឺជាផ្នែកមួយនៃគម្រោងសាកល្បងដែលគាំទ្រដោយ យូអិនឌីភី ដើម្បីកែលម្អចំណេះដឹង និងជំនាញរបស់មន្ត្រីខេត្ត និងជនបង្គោលនានា លើការតាមដាននិងវាយតម្លៃ។ គម្រោងនេះជួយពង្រឹងប្រព័ន្ធ និងរចនាសម្ព័ន្ធរដ្ឋបាលនៅមូលដ្ឋាន និងផ្តល់ឱ្យពួកគេនូវ អំណាចធ្វើសេចក្តីសម្រេចកាន់តែច្រើនជាងមុន និងដើម្បីអាចឱ្យពួកគេផ្តល់សេវាកម្មបានឆាប់រហ័សជាងមុនទៅដល់ប្រជាពលរដ្ឋ នៅមូលដ្ឋាន។*

# ដោយសារកិច្ចប្រឹងប្រែងអភិរក្សរបស់អ្នកភូមិ ត្រីក៏សម្បូរឡើងវិញ



UNDP PHOTO / ISABELLE LESSER

*អ្នកស្រុកនាំគ្នាលើកមងចាប់ត្រីនៅក្នុងបឹងក្រចាប់ ភូមិពាមជ្រៃ ខេត្តកំពង់ឆ្នាំង។ បឹងក្រចាប់ ដែលពីមុនសឹងតែផុតពូជត្រីទៅហើយនោះ ឥឡូវនេះសម្បូរត្រីឡើងវិញ ដោយសារកិច្ចប្រឹងប្រែងអភិរក្សរបស់អ្នកស្រុកក្នុងភូមិពាមជ្រៃ។*

នៅពេលរាត្រី លោក ខាត់ ឃន អុំទូកតូចមួយនៅក្នុងបឹង នៅខាងក្រោយភូមិរបស់គាត់ក្នុងខេត្តកំពង់ឆ្នាំង តែមិនមែនដើម្បីនេសាទត្រីទេ គឺដើម្បីរក់មើលក្រែងលោមានអ្នកមកចូលលួចនេសាទ។ ជាផ្លូវទៅនឹងទង្វើរបស់គាត់ ជនកម្ពុជាអាយុ ៤៩ឆ្នាំ រូបនេះ តែងទទួលបាននូវការគំរាមកំហែងជាច្រើនមកលើអាយុជីវិតរបស់គាត់ ប៉ុន្តែគាត់មិនព្រមចុះញ៉មចំពោះការគំរាមកំហែងនោះឡើយ។

លោក ខាត់ ឃន ដែលមានវិទ្យុទាក់ទងនៅក្នុងដៃសម្រាប់ប្រើប្រាស់នៅពេលល្បាតបានពោលថា "ការរស់រានរបស់យើងទៅអនាគតពឹងផ្អែកលើត្រីនៅក្នុងបឹងនេះ ដូច្នេះខ្ញុំមិនអាចរុញរាដោយសារតែការគំរាមកំហែងពីពួកគេឡើយ"។

គាត់ជាមនុស្សម្នាក់ក្នុងចំណោមអ្នកភូមិ ដែលបានពួតដៃគ្នាឡើងដើម្បីថែរក្សា បឹងក្រចាប់ នៅក្នុងភូមិពាមជ្រៃ ខេត្តកំពង់ឆ្នាំង។ ពួកគាត់បានទទួលការលើកទឹកចិត្តឱ្យធ្វើសកម្មភាពនេះដោយសារការព្រួយបារម្ភមួយថាការនេសាទដែលគ្មានការត្រួតពិនិត្យប្រព្រឹត្តទៅជាយូរមកហើយពីសំណាក់អ្នកភូមិជាមួយគ្នា កំពុងបានគំរាមកំហែងធ្វើឱ្យបាត់បង់ពូជនៃប្រភេទត្រីនានានៅក្នុងបឹងនេះ។ សព្វថ្ងៃនេះកិច្ចប្រឹងប្រែងរបស់ពួកគេបានផ្តល់ផលមកវិញហើយ។ យោងតាមអ្នកភូមិខ្លះៗ ត្រីនៅក្នុងបឹងនេះសម្បូរឡើងវិញ ហើយនៅក្នុងរដូវប្រាំងពួកគេអាចចាប់ត្រីបានដោយដៃទទេថែមទៀតផង។

ដើម្បីធ្វើឱ្យត្រីសម្បូរឡើងវិញ ពួកគេបានបង្កើតតំបន់ការពារធម្មជាតិមួយទំហំបីហិកតា។ តំបន់ការពារធម្មជាតិគឺជាផ្នែកមួយនៃតំបន់វាលភក់ដែលមានទំហំប្រាំពីរហិកតានៅលើកោះមួយក្នុងដងទន្លេសាប។ នៅក្រោមផ្ទៃទឹកមានលូបេតុង ចំនួន ៣៥ ដែលលូនីមួយៗមានអង្កត់ផ្ចិតទំហំមួយម៉ែត្រ ត្រូវបានដាក់ពន្លិចនៅក្នុងបឹងនេះដើម្បីផ្តល់ជាជម្រកសម្រាប់ត្រី។ តំបន់នេះ ដែលហ៊ុំព័ទ្ធជុំវិញដោយលួសបន្លា គឺជាតំបន់ហាមឃាត់ការនេសាទ ប៉ុន្តែអ្នកភូមិនានាអាចធ្វើនេសាទនៅក្នុងតំបន់ជុំវិញកន្លែងការពារនេះ។

លោក អៀង ផល្លា មេដឹកនាំអភិរក្សនៅក្នុងភូមិបានពោលថា "ការព័ទ្ធរបងមានសារៈសំខាន់ណាស់សម្រាប់ត្រីពង ហើយដល់ពេលកូនត្រីវាធំឡើងវាអាចសាយភាយពីទីនេះទៅកន្លែងដទៃនៅខាងក្រៅ"។

ត្រីគឺជាប្រភពចំបងមួយនៃប្រូតេអ៊ីនសម្រាប់ប្រជាជនកម្ពុជា ដែលភាគច្រើនរស់នៅជនបទ។

កសិករនៅភូមិពាមជ្រៃ នៅចាំបានថាកាលពីមុនពួកគាត់មិនអាចនេសាទត្រីបានគ្រប់គ្រាន់សម្រាប់ការបរិភោគប្រចាំថ្ងៃឡើយ។ ការនេសាទធ្លាប់តែបានធ្វើឡើងតាមគ្រប់រូបភាព។ អ្នកភូមិប្រើប្រាស់ឧបករណ៍អគ្គិសនីដើម្បីឆក់ត្រី។ ក្នុងករណីខ្លះពួកគាត់ធ្លាប់ប្រើប្រាស់អួនក្រឡាល្អិត ដូចជា ស្បៃមុង ដែលចាប់បានមិនត្រឹមតែត្រីធំនោះទេ ប៉ុន្តែត្រីល្អិតៗផងដែរ។

ប៉ុន្តែកាលពីបីឆ្នាំមុននេះ ក្រោយបានទទួលមូលនិធិគាំទ្រពី យូអិនឌីភី សហគមន៍នេះបានចាប់ផ្តើមបង្កើតជាក្រុមអភិរក្សមួយ។ ការងារនេះរួមបញ្ចូលអ្នកភូមិធ្វើការល្បាតបឹងនេះនៅពេលយប់ ដែលជាពេលតែងតែមានការលួចចូលនេសាទ។ ពួកគេធ្វើការប្តូរវេន និងដោយស្ម័គ្រចិត្ត ហើយមិនមែនមានតែបុរសប៉ុណ្ណោះទេដែលចូលរួមនៅក្នុងការងារនេះ។

លោកស្រី ផាន់ សារុធ អាយុ ៥១ឆ្នាំ ដែលស្ថិតក្នុងក្រុមល្បាតដែរនោះបានពោលថា "កាលពីមុន ខ្ញុំធ្លាប់តែខ្លាចអ្នកចូលលួច ប៉ុន្តែសព្វថ្ងៃនេះ ខ្ញុំគិតថាពួកគេខ្លាចយើងជាង"។ គាត់បានពោលថា ក្រោយចាប់បានអ្នកចូលលួចនេសាទតាមធម្មតាត្រូវបានផាកពិន័យ និងបង្ខំឱ្យចុះកិច្ចសន្យាមិនប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ទៀតឡើយ។ លោកស្រី ផាន់ សារុធ ដែលជាប្រធានក្រុមសន្សំប្រាក់នៅក្នុងភូមិ ដែលកៀងគរប្រាក់សម្រាប់ឱ្យសមាជិកខ្ចីក្នុងគ្រាបន្ទាន់ និងតាមអត្រាការប្រាក់ទាបបានមានប្រសាសន៍បន្ថែមទៀតថា "ចំនួនអ្នកចូលលួចនេសាទបានថយចុះ ដោយសារការប្រុងប្រយ័ត្នរបស់យើង"។

នៅពេលដែលការគាំទ្រខាងហិរញ្ញវត្ថុរបស់ យូអិនឌីភី សម្រាប់កិច្ចផ្តួចផ្តើមនេះបានបញ្ចប់នៅក្នុងឆ្នាំ ២០០៧ លោក អៀង ផល្លា ដែលជាមេដឹកនាំអភិរក្សនៅក្នុងភូមិរម្លឹកឡើងវិញអំពីការព្រួយបារម្ភថា អ្នកស្ម័គ្រចិត្តនានានឹងបាត់បង់ទឹកចិត្ត ដែលអាចធ្វើឱ្យបឹងនេះវិលត្រឡប់ទៅរកស្ថានភាពនៃការលួចនេសាទដូចកាលពីមុន។ ប៉ុន្តែគាត់និយាយថា "ការប្តេជ្ញាមោះមុត" របស់អ្នកភូមិដើម្បីការពារប្រភពចំបងមួយសម្រាប់ការចិញ្ចឹមជីវិត បានបង្ហាញថាគាត់បានយល់ខុសហើយ។

លោក ឌួង សុផាត មេដឹកនាំអភិរក្ស នៅក្នុងភូមិទឹកហូត ដែលស្ថិតនៅចម្ងាយប្រមាណមួយម៉ោងពីពាមជ្រៃ បើធ្វើដំណើរតាមទូកបានពោលថា ការអភិរក្សបឹងមិនគ្រាន់តែអាចធ្វើឱ្យចំនួនត្រីកើនឡើងវិញប៉ុណ្ណោះទេ តែវាក៏ជួយរក្សាភាពសុខដុមរមនារវាងសហគមន៍នៅមូលដ្ឋានផងដែរ។ គាត់បានរម្លឹកឡើងវិញអំពីស្ថានភាពដែលការនេសាទច្រើនហួសហេតុ នៅក្នុងបឹងជើងដីរនៅក្នុងភូមិរបស់គាត់ ធ្លាប់តែបានបង្ខំឱ្យអ្នកភូមិធ្វើដំណើររសាត់ទៅតាមសហគមន៍ដទៃទៀត ដើម្បីធ្វើនេសាទ ដែលជាហេតុធ្វើឱ្យអ្នកភូមិជិតខាងខ្លះមិនសប្បាយចិត្ត។

ប៉ុន្តែប្រការនេះលែងនៅជាបញ្ហាទៀតហើយ ក្រោយពេលដែលក្រុមអភិរក្សបឹងនេះ ត្រូវបានបង្កើតឡើងនៅក្នុងភូមិរបស់គាត់កាលពីបីឆ្នាំកន្លងទៅ ក្រោមការជួយគាំទ្រពី យូអិនឌីភី។ ជារៀងរាល់យប់អ្នកស្ម័គ្រចិត្តចំនួន ១៥នាក់បានប្តូរវេនគ្នាដើម្បីការពារត្រី។ ដោយសារកិច្ចប្រឹងប្រែងរបស់សហគមន៍នេះគាត់បានពោលថា នៅពេលថ្មីៗនេះបឹងនេះបានក្លាយជាទីដៅសម្រាប់ ការនេសាទកំសាន្តសម្រាប់មនុស្សម្នាមកពីទីប្រជុំជនដទៃផងដែរ។

# អ្នកផលិតប្រហុកបង្កើតជាសមាគម ដើម្បីពង្រីកឱកាសខាងទីផ្សារ

ប្រហុក ដែលជាផលិតផលត្រីផ្អាប់នៅកម្ពុជា គឺជាធាតុផ្សំដ៏សំខាន់មួយនៅក្នុងការចំអិនអាហាររបស់ខ្មែរ។ អស់ជាច្រើនជំនាន់មកហើយដែលប្រហុកស និងគ្មានឆ្អឹង ឬ "ប្រហុកអប់" ត្រូវបានគេស្គាល់ថាមានគុណភាពល្អបំផុត ដែលផលិតឡើង ដោយគ្រួសារនានានៅក្នុងឃុំកំពង់ឃ្លាំង ដែលតាំងនៅតាមមាត់បឹងទន្លេសាប។

ប៉ុន្តែការផលិតប្រហុកនេះកំពុងថយចុះ។ មានតែប្រមាណ ៣០ គ្រួសារ ក្នុងចំណោម ១.៩៨៦ គ្រួសារនៅក្នុងឃុំក្រីក្រមួយនេះនៃខេត្តសៀមរាប ដែលនៅតែបន្តផលិតប្រហុកបែបនេះដោយប្រើប្រាស់ត្រីល្អិតៗ ដែលជាត្រីកំភ្លាញ។

គ្រួសារជាច្រើនមើលឃើញថា ពួកគេមានភាពងាយស្រួល និងបានផលច្រើនជាងដោយគ្រាន់តែលក់ត្រីក្នុងបរិមាណច្រើន ធៀបនឹងការកែច្នៃផលត្រីទាំងនោះទៅជាប្រហុក។ បើទោះជាអ្នកភូមិសម្រេចចំណាយពេលវេលា និងកិច្ចប្រឹងប្រែងរបស់ខ្លួននៅក្នុងដំណើរការផលិតប្រហុកនេះក៏ដោយ ជាញឹកញាប់គឺអ្នកលក់ដុំប្រហុក មិនមែនអ្នកផលិតប្រហុកទេ ដែលទទួលផលចំណេញភាគច្រើនពីតម្លៃបន្ថែមក្នុងរបរនេះ។

កិច្ចប្រឹងប្រែងមួយកំពុងត្រូវបានអនុវត្ត ដើម្បីដាក់ឱ្យសិប្បកម្មនេះមានដំណើរការឡើងវិញ។ ក្រសួងពាណិជ្ជកម្មបានជួយ បង្កើតសមាគមផលិតប្រហុកអប់នៅកំពង់ឃ្លាំង ដើម្បីជួយអ្នកភូមិបង្កើនតម្លៃបន្ថែមពីការផលិតប្រហុកនៅក្នុងភូមិនេះ ។

សមាគមអ្នកផលិតប្រហុក គឺជាសមាគមដំបូងបង្អស់នៅក្នុងប្រទេសនេះ ហើយក្រសួងនេះមានគោលដៅផ្តល់សេវាកម្មខាងផ្នែកអាជីវកម្ម ឱ្យដល់គ្រួសារជាច្រើនដើម្បីជួយពួកគេក្នុងការរកប្រាក់ចំណូល និងប្រយុទ្ធប្រឆាំងភាពក្រីក្រ។

ឯកឧត្តម ម៉ៅ ថូរ៉ា រដ្ឋលេខាធិការដែលដឹកនាំគម្រោង TRADE នៃក្រសួងពាណិជ្ជកម្មជាមួយការគាំទ្រពីអង្គការយូអិនឌីភី មានប្រសាសន៍ថា "នៅក្នុងរយៈពេលពីរឆ្នាំខាងមុខនេះយើងនឹងបន្តគាំទ្រ និងពង្រឹងសមាគមនេះដោយផ្តល់សេវាកម្មហិរញ្ញវត្ថុ និងធ្វើការតាមដានជាទៀងទាត់អំពីការរីកចម្រើនដែលសមាគមនេះបានអនុវត្ត"។

នៅក្នុងកិច្ចប្រឹងប្រែងមួយដើម្បីជួយសមាគមនេះក្នុងការលើកកំពស់ការផលិតប្រហុកអប់ ក្រសួងបានផ្តល់យុទ្ធសាស្ត្រសម្រាប់ការលក់ផលិតផលដោយការដាក់យីហោផលិតផល លទ្ធភាពទទួលបានមីក្រូហិរញ្ញវត្ថុ និងកែលម្អស្តង់ដារអនាម័យ។

ដើម្បីផលិតប្រហុក អ្នកភូមិហូតយកសាច់ត្រី បុកសាច់ត្រីដើម្បីឱ្យសាច់វាបែកនិងស្អិតជាប់គ្នា បន្ទាប់មកប្រឡាក់អំបិលរួចផ្អាប់ទុករយៈពេលបីខែ។ ប្រហុកភាគច្រើនមានពណ៌ពីប្រផេះទៅពណ៌ត្នោត មិនដូចជាប្រហុកអប់ពណ៌សមកពីឃុំកំពង់ឃ្លាំងឡើយ។

ប្រហុក គឺជាគ្រឿងផ្សំចំបងមួយនៅក្នុងការចំអិនអាហាររបស់ខ្មែរ។ ជាទូទៅគេចាត់ទុកថាជាគ្រឿងផ្សំអាហារដែលមានក្លិនខ្លាំង និងប្រៃ។ ទោះជាយ៉ាងណាក៏ដោយវាក៏ផ្តល់នូវប្រូតេអ៊ីន និងអាហារូបត្ថម្ភដ៏សំខាន់ក្នុងអាហារដែលមានបាយ ដើរតួនាទីជាមូលដ្ឋាននោះ។

នៅក្នុងយុទ្ធសាស្ត្ររបស់ក្រសួង ប្រហុកអប់ នឹងទទួលបានសញ្ញាមួយ នៅក្រោមប្រព័ន្ធសន្ទស្សន៍ភូមិសាស្ត្រថ្មីដែលនឹងផ្តល់នូវការបញ្ជាក់អំពីប្រភពដើមរបស់ផលិតផលនេះ។ គំរូនៃការវេចខ្ចប់ និងការដាក់ស្លាកសញ្ញាត្រូវបានបង្កើតរួចហើយ។

អ្នកភូមិប្រមាណ ៦៨នាក់ មកពីភូមិចំនួនប្រាំពីរនៅក្នុងឃុំកំពង់ឃ្លាំង បានជួបជុំគ្នានៅក្នុងវត្តមួយក្នុងភូមិ កាលពីខែមីនា ដើម្បីបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាសមាគមនេះ។ ភាគច្រើននៃសមាជិកដែលបានជ្រើសរើសនេះគឺជាស្ត្រី។ ប្រាក់វិភាគទានសមាជិកភាពសម្រាប់មួយអាយុកាលគឺ ១០.០០០ រៀល (២,២៥ ដុល្លាអាមេរិក)។

ប្រធានឃុំកំពង់ឃ្លាំង លោក ទុយ ងាម អាយុ ៥៩ ឆ្នាំ បានពោលថា សមាគមនេះនឹងក្លាយជាបណ្តាញសុវត្ថិភាពមួយ សម្រាប់អ្នកមូលដ្ឋានតាមរយៈការផលិត និងលក់ប្រហុក និងបង្កើតជាសម្លេងឯកភាពគ្នាមួយនៅក្នុងសហគមន៍អ្នកនេសាទ។

លោកបានពោលថា "អ្នកនេសាទនិងអ្នកផលិតប្រហុកនឹងអាចទទួលបានប្រាក់កាន់តែច្រើនពីផលិតផលត្រីរបស់ពួកគេ។ ប្រាក់ចំណូលកាន់តែច្រើន នឹងកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ពួកគាត់"។

នៅក្នុងការឈានទៅបញ្ចូលផលិតផលនេះទៅក្នុងទីផ្សារឱ្យបានទូលំទូលាយ ក្រសួងបានទិញប្រហុកអប់



UNDP PHOTO

*អ្នកស្រុកនៅឃុំកំពង់ឃ្លាំង ខេត្តសៀមរាប កំពុងសំអាតត្រីកំភ្លាញដើម្បីធ្វើប្រហុកអប់ ។ក្រសួងពាណិជ្ជកម្មបានជួយបង្កើតសមាគមផលិតប្រហុកអប់នៅកំពង់ឃ្លាំង ដើម្បីជួយអ្នកភូមិបង្កើនតម្លៃបន្ថែមពីការផលិតប្រហុក និងពង្រីកឱកាសខាងទីផ្សារឱ្យពួកគេ ។*

១០០ គ.ក្រ ពី សមាគមនេះដោយបានវេចខ្ចប់ និងលក់ផលិតផលនេះនៅក្នុងសន្និសីទនៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចនៅអាស៊ាន ក្នុងខែឧសភា នៅខេត្តសៀមរាប។ ប្រហុកមួយកែវចំណុះកន្លះគីឡូ ត្រូវបានលក់តាមតម្លៃ ១២.០០០ រៀល (៣ ដុល្លាអាមេរិក)។ ផលចំណូលត្រូវបានបញ្ចូលទៅឱ្យសមាគមនេះវិញ។

គម្រោងនៅឃុំកំពង់ឃ្លាំង គឺជាឧទាហរណ៍មួយអំពីថាតើក្រសួងពាណិជ្ជកម្ម កំពុងធ្វើការបែបណាជាមួយសហគមន៍នៅមូលដ្ឋាននៅទូទាំងប្រទេសកម្ពុជា ដើម្បីពង្រីកឱកាសខាងទីផ្សារសម្រាប់អ្នកភូមិក្រីក្រនៅជនបទ។

ឯកឧត្តម ម៉ៅ ថូរ៉ា បានពោលថា ក្រសួងចង់បន្តទំនាក់ទំនងរបស់ខ្លួនជាមួយសហគមន៍នៅជនបទ ដើម្បីបង្កើតឱ្យមានសមាគមកសិ-ពាណិជ្ជករ សម្រាប់ជម្រុញផលិតផលនៅក្នុងមូលដ្ឋាន ដែលអនុញ្ញាតឱ្យអ្នកក្រីក្រក្នុងភូមិ រកប្រាក់ចំណូលបានកាន់តែច្រើនជាងមុន និងដើម្បីកែលម្អស្តង់ដារនៃការរស់នៅរបស់ពួកគេ។

## *វិស័យនានានៃកម្មវិធីរបស់យូអិនឌីភី*

*ការិយាល័យ យូអិនឌីភី នៅកម្ពុជាគឺជាវត្តមានថ្នាក់ជាតិរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំប្រទេសកម្ពុជា ។ អង្គការនេះជួយពលរដ្ឋកម្ពុជាស្វែងរកដោយខ្លួនឯងនូវដំណោះស្រាយរបស់គេចំពោះភាពប្រឈមនានានៅក្នុងការអភិវឌ្ឍ ។ យូអិនឌីភី នៅកម្ពុជាផ្តោតលើផ្នែកជាសំខាន់បីគឺ : ការកាត់បន្ថយភាពក្រីក្រ ថាមពល និងបរិស្ថាន និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។*

## *ការកាត់បន្ថយភាពក្រីក្រ*

*យូអិនឌីភី ធ្វើការជាមួយរដ្ឋាភិបាល ម្ចាស់ជំនួយមកពីក្រៅប្រទេស និងសង្គមស៊ីវិលដើម្បីកាត់បន្ថយភាពក្រីក្រនៅទូទាំងប្រទេសតាមរយៈការគាំទ្រដល់កិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រ ។ កិច្ចប្រឹងប្រែងទាំងនេះជួយពង្រឹងសមត្ថភាពដឹកនាំរបស់រដ្ឋាភិបាលផ្តល់លទ្ធភាពបានប្រសើរជាងមុន ក្នុងការទទួលបានព័ត៌មានសម្រាប់ការបង្កើតគោលនយោបាយមានប្រសិទ្ធិភាពក្នុងការបម្រើដល់អ្នកក្រីក្រជំរុញវិស័យពាណិជ្ជកម្ម និងការអភិវឌ្ឍវិស័យឯកជនដើម្បីជួយជនក្រីក្រ និងផ្តោតលើការសម្របសម្រួលជំនួយឱ្យមានប្រសិទ្ធិភាពដើម្បីឱ្យរាល់ប្រាក់ដុល្លារដែលត្រូវបានចំណាយ អាចផ្តល់មកវិញនូវផលជាអតិបរមា។*

## *ថាមពលនិងបរិស្ថាន*

*មានភាពជាបន្ទាន់ក្នុងការធ្វើសកម្មភាពដើម្បីដោះស្រាយភាពប្រឈមផ្នែកបរិស្ថាន និងថាមពលរបស់ប្រទេសកម្ពុជា។ ជនក្រីក្រទទួលរងផលប៉ះពាល់ ក្នុងកម្រិតវិសមាមាត្រដោយសារការរេចរឹលនៃបរិស្ថាន និងកង្វះលទ្ធភាព ដើម្បីទទួលបានសេវាកម្មថាមពលស្អាតដែលអាចជាវបាន ។ យូអិនឌីភី កំពុងជួយបណ្តុះទស្សនៈទានរយៈពេលយូរអង្វែងមួយអំពី ការគ្រប់គ្រងធនធានធម្មជាតិរបស់កម្ពុជា នៅក្នុងតំបន់ភូមិសាស្ត្រដែលងាយខូចខាតបំផុតខ្លះៗនៅក្នុងប្រទេសនេះ។*

## *អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ*

*ភាពប្រឈមសម្រាប់ប្រទេសកម្ពុជានៅក្នុងការកសាងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ គឺការបង្កើតស្ថាប័ន និងដំណើរការដែលមានការឆ្លើយតបជាងមុនទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋសាមញ្ញ ដែលរួមទាំងជនក្រីក្រផង និងលើកកំពស់ការអភិវឌ្ឍ។ យូអិនឌីភី ជួយពង្រឹងប្រព័ន្ធបោះឆ្នោត និងប្រព័ន្ធច្បាប់ កែលម្អលទ្ធភាពទទួលបានយុត្តិធម៌ និងរដ្ឋបាលសាធារណៈ និងអភិវឌ្ឍន៍សមត្ថភាពកាន់តែច្រើនថែមទៀត ដើម្បីផ្តល់សេវាកម្មជាមូលដ្ឋាន ដល់អ្នក ដែលត្រូវការសេវាកម្មនោះបំផុត។*

*អាគារលេខ ៥៣ វិថី ប៉ាស្ទ័រ*
*សង្កាត់ បឹងកេងកង*
*ប្រអប់សំបុត្រលេខ ៨៧៧*
*ក្រុងភ្នំពេញ*
*ព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ : +855 (0) 23 216 167*
*ទូរសារ : +855 (0) 23 216 257*
*អ៊ីម៉ែល : registry.kh@undp.org*
*វេបសាយ : www.un.org.kh/undp/*

## ផ្នែកទំនាក់ទំនង

*អេមី ប្រោន*
*អ្នកឯកទេសព័ត៌មានសាធារណៈ*
*ម៉ាការេណា អាហ្គីឡារ*
*ទីប្រឹក្សាផ្នែកទំនាក់ទំនងនៃកម្មវិធី*
*កែ មុនធិត*
*មន្ត្រីព័ត៌មានសាធារណៈ និងបណ្តាញផ្សព្វផ្សាយ*
*សេង បុប្ផា*
*មន្ត្រីវិភាគផ្នែកទំនាក់ទំនងនៃកម្មវិធី*
*កន សង្ហាក់*
*ជំនួយការផ្នែកទំនាក់ទំនង*